ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០០៣-០០៧ ប្រ.ក

# ប្រកាស
## ស្តីពី
## ការកំណត់អត្រាការប្រាក់បញ្ញើមានកាលកំណត់

### ទេសាភិបាលធនាគារជាតិ នៃ កម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស-រកត ០២០២-០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- បានឃើញប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ លេខធ.៨៩៨-៣៨៥ ប្រក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៨
- តាមសំណើរបស់អគ្គនាយក
- តាមការសំរេចរបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៣

## សំ រេ ច

**ប្រការ១.-** កំណត់អត្រាការប្រាក់បញ្ញើមានរយៈពេលកំណត់ជារៀល និងជាដុល្លារអាមេរិកសំរាប់ផ្តល់ជូនអតិថិជនដែលបានផ្ញើប្រាក់នៅធនាគារជាតិនៃកម្ពុជា ក្រៅពីអតិថិជនជាស្ថាប័នរដ្ឋពាក់ព័ន្ធជាមួយថវិកាដូចតទៅ:

ក- អត្រាការប្រាក់បញ្ញើជារៀល

- ប្រាក់បញ្ញើមានរយៈពេលកំណត់៣ខែ ១.០០% ក្នុងមួយឆ្នាំ
- ប្រាក់បញ្ញើមានរយៈពេលកំណត់៦ខែ ១.២០ % ក្នុងមួយឆ្នាំ
- ប្រាក់បញ្ញើមានរយៈពេលកំណត់១ឆ្នាំ ២.០០ % ក្នុងមួយឆ្នាំ

ខ- អត្រាការប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិក ត្រូវគិតតាមអត្រា៦/៨ នៃ SIBOR (Singapore Inter-Bank Offered Rate) ។

**ប្រការ២.-** អត្រាការប្រាក់ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៣ តទៅរហូតដល់មានការកែប្រែជាថ្មី ។

**ប្រការ៣.-** រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៤.-** អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់សាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ៥..** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ០៩ ខែមករា ឆ្នាំ ២០០៣

ទេសាភិបាល

ជា_ចាន់តូ

**កន្លែងទទួល:**

- ដូចប្រការ៤ (ដើម្បីអនុវត្ត)
- កាលប្បវត្តិ
- ឯកសារ

**ចំលងជូន:**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណ:រដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃ ទីស្តីការគណ:រដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"